**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# លិខិតជូនពរ

## គោរពជូន
## ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាអគ្គមេបញ្ជាការកងទ័ពជើងគោក

ឯកឧត្តមបណ្ឌិត ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ!

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរប្រកបដោយទឹកចិត្តសប្បាយរីករាយក្រៃលែង ក្នុងឱកាសដែល **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** ត្រូវបានព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គសព្វព្រះរាជហឫទ័យ ដំឡើងឋានន្តរស័ក្តិជា "**នាយឧត្តមសេនីយ៍**"។

ការដំឡើងឋានន្តរស័ក្តិជា "**នាយឧត្តមសេនីយ៍**" នេះពិតជាស័ក្តិសមនឹងសមត្ថភាព ស្នាដៃ ចំណេះដឹង គុណធម៌ និងការលះបង់កម្លាំងកាយចិត្តយ៉ាងធំធេងដែលមិនអាចកាត់ថ្លៃបានរបស់ **ឯកឧត្តមបណ្ឌិត** ចំពោះជាតិមាតុភូមិ និងប្រជាជនកម្ពុជាប្រកបដោយទឹកចិត្តស្មោះសរក្នុងបុព្វហេតុនៃការចូលរួមចំណែករក្សាការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងវឌ្ឍនភាពសេដ្ឋកិច្ច-សង្គមកម្ពុជា បម្រើឱ្យការរីកចម្រើនរបស់សង្គមជាតិ ក៏ដូចជាសុភមង្គល និងភាពសុខដុមរមនារបស់ប្រជាជាតិខ្មែរទាំងមូល។

ដោយសារទឹកចិត្តនិងកាយវិការស្នេហាមាតុភូមិនិងប្រជាជនកម្ពុជា របស់ **ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ុន ម៉ាណែត** នៅគ្រប់កាលៈទេសៈ យើងខ្ញុំទាំងអស់គ្នា ប្តេជ្ញាគាំទ្រឥតងាករេនៅគ្រប់កាលៈទេសៈទាំងអស់ ក្នុងឆន្ទៈដ៏មោះមុត ជាមួយ **ឯកឧត្តម នាយឧត្តមសេនីយ៍** ដើម្បីចូលរួមរក្សាឱ្យបានជាដាច់ខាតនូវសន្តិភាព វិបុលភាព និងសេចក្តីសុខក្សេមក្សាន្តជាដរាបរបស់ជាតិនិងប្រជាជនកម្ពុជា។

ឆ្លៀតក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយថែរក្សាការពារ **ឯកឧត្តម នាយឧត្តមសេនីយ៍** និង **លោកជំទាវ** ព្រមទាំង **បុត្រា បុត្រី** សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ព្រមទាំងទទួលបានសព្វសាធុការពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសម្រេចបានដូចបំណងប្រាថ្នា... 

សូម **ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ុន ម៉ាណែត** ទទួលនូវការស្រឡាញ់ រាប់អានដ៏ជ្រាលជ្រៅពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃសុក្រ ១១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ សុខា**